# ការក្លាយជាល្អឥតខ្ចោះនៅក្នុងព្រះយេស៊ូវគ្រីស្ទ

សូមអានបទគម្ពីរយោងខាងក្រោមនេះ ។ សូមរកមើលឃ្លាដែលបង្កើនទំនុកចិត្តរបស់អ្នកថា ព្រះអង្គសង្គ្រោះអាចជួយយើងឲ្យយកឈ្នះលើភាពមិនល្អឥតខ្ចោះរបស់យើង ហើយក្លាយទៅដូចទ្រង់កាន់តែខ្លាំងឡើង ។ អ្នកអាចធ្វើបញ្ជីមួយអំពីអ្វីដែលអ្នករកឃើញនៅក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នក ឬនៅខាងក្រោយសំណៅចែកនេះ ។

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦:៤០–៤២

អេធើរ ១២:២៧

មរ៉ូណៃ ១០:៣២–៣៣

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ។ ស្វែងរកអ្វីដែលយើងអាចធ្វើដើម្បីយកឈ្នះលើការគិតបែបឥតខ្ចោះនិយម ហើយផ្ដោតលើការក្លាយជាមនុស្សកាន់តែប្រសើរតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចគូសចំណាំនៅលើឃ្លាដែលលេចធ្លោចំពោះអ្នក ។

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីអ្វីដែលព្រះអម្ចាស់ធ្វើ ហើយមិនរំពឹងពីយើងឡើយ ៖



ព្រះមិនត្រូវការមនុស្សដែលល្អឥតខ្ចោះនោះទេ ។ ទ្រង់ស្វែងរកអស់អ្នកដែលនឹងផ្ដល់ « ចិត្ត និងគំនិតដែលស្ម័គ្រតាម » [ គោលលទ្ធិ និងសេចក្ដីសញ្ញា ៦៤:៣៤ ] ហើយទ្រង់នឹងធ្វើឲ្យពួកគេ « បានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ » [ មរ៉ូណៃ ១០:៣២–៣៣ ] ។ ( ឌៀថើរ អេហ្វ អុជដូហ្វ « Five Messages That All of God’s Children Need to Hear » [ ការប្រជុំធម្មនិដ្ឋាននៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី១៧ ឆ្នាំ២០២១ ] ទំព័រ ៣ នៅលើគេហទំព័រ speeches.byu.edu )

ប្រធាន រ័សុល អិម ណិលសុន បានពន្យល់អំពីអ្វីដែលយើងអាចធ្វើបាននៅពេលយើងឃើញភាពមិនល្អឥតខ្ចោះរបស់យើង ៖



សូមឲ្យយើងធ្វើអ្វីដែលល្អបំផុតដែលយើងអាចធ្វើបាន ហើយព្យាយាមធ្វើឲ្យប្រសើរឡើងជារៀងរាល់ថ្ងៃ ។ នៅពេលភាពមិនល្អឥតខ្ចោះរបស់យើងលេចឡើង យើងអាចបន្តព្យាយាមកែតម្រូវវាបាន ។ យើងអាចអភ័យទោសចំពោះកំហុសនៅក្នុងខ្លួនយើង និងក្នុងចំណោមអស់អ្នកដែលយើងស្រឡាញ់បាន ។ ( រ័សុល អិម ណិលសុន « Perfection Pending » *Ensign* ខែវិច្ឆិកា ឆ្នាំ១៩៩៥ ទំព័រ ៨៨ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_576-1